ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០២២-០៥៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូល លោហធាតុ និងត្បូងថ្មមានតម្លៃ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៩/៦៤២ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៨៩៧/០៣ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៨៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ១២ និងប្រការ ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមការចាំបាច់របស់ធនាគារជាតិនៃកម្ពុជា

## សម្រេច

**ប្រការ ១.**

ប្រកាសនេះមានគោលបំណងគ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលធ្វើអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃដែលត្រូវចាត់ទុកជារូបិយបណ្ណ។

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុនទាំងឡាយណា ដែលមានបំណងធ្វើអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.**

លោហធាតុ និងត្បូងថ្មមានតម្លៃដែលត្រូវចាត់ទុកជារូបិយបណ្ណនៅក្នុងប្រកាសនេះត្រូវបានកំណត់ដូចតទៅ ៖

**១/- លោហធាតុមានតម្លៃ** សំដៅដល់ មាស ប្រាក់ ប្លាទីន ដែលមិនទាន់ច្នៃជាគ្រឿងអលង្ការ។
**២/- ត្បូងថ្មមានតម្លៃ** សំដៅដល់ ត្បូងថ្មដែលមិនទាន់ច្នៃជាគ្រឿងអលង្ការ។

**ប្រការ ៣.**

អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃត្រូវតែជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ឬក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។ ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវភ្ជាប់ជាមួយនូវ៖

ក. លក្ខន្តិកៈគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (ប្រសិនបើអ្នកដាក់ពាក្យសុំជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ)
ខ. លក្ខន្តិកៈក្រុមហ៊ុនដែលមានកម្មវត្ថុចម្បងធ្វើអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ
គ. លិខិតបញ្ជាក់ពីការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដែលចេញដោយក្រសួងពាណិជ្ជកម្ម
ឃ. លិខិតបញ្ជាក់អាសយដ្ឋានប្រកបអាជីវកម្មពីអាជ្ញាធរមូលដ្ឋាន
ង. អត្តសញ្ញាណប័ណ្ណរបស់អ្នកគ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុននិងអាសយដ្ឋានរស់នៅបច្ចុប្បន្ន
ច. រចនាសម្ព័ន្ធគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុន
ឆ. ដើមទុន និងផែនការអាជីវកម្មរបស់ក្រុមហ៊ុនស្តីពីអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ
ជ. ឯកសារផ្សេងៗទៀតតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

ទន្ទឹមនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវមានប្រព័ន្ធចុះកិច្ចបញ្ជិកាគណនេយ្យសមស្រប។

**ប្រការ ៤.**

នៅក្នុងការពិនិត្យលើពាក្យស្នើសុំអាជ្ញាបណ្ណ ធនាគារជាតិនៃកម្ពុជានឹងពិចារណាលើលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របក្នុងការផ្តល់អាជ្ញាបណ្ណ។ ធនាគារជាតិនៃកម្ពុជានឹងបដិសេធពាក្យស្នើសុំអាជ្ញាបណ្ណណាដែលមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់។

អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតចំនួន ២.០០០.០០០ រៀល (ពីរលានរៀល)។

**ប្រការ ៥.**

អាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុនិងត្បូងថ្មមានតម្លៃមានសុពលភាព ៣ឆ្នាំ (បីឆ្នាំ)។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុនដែលមានបំណងចង់បន្តអាជីវកម្មត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណថ្មីឱ្យបាន ៣០ថ្ងៃ មុនអាជ្ញាបណ្ណចាស់អស់សុពលភាព។

អាជ្ញាបណ្ណនេះមានតម្លៃប្រើប្រាស់សម្រាប់តែគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុន ដែលមានឈ្មោះក្នុងអាជ្ញាបណ្ណប៉ុណ្ណោះ។

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវបង់សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំចំនួន ៥.០០០.០០០ រៀល (ប្រាំលានរៀល) នៅពេលបានទទួលអាជ្ញាបណ្ណ និងត្រូវបង់ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ សម្រាប់ឆ្នាំបន្ទាប់។

ក្នុងករណីប្តូរអាជ្ញាបណ្ណថ្មី ដោយមូលហេតុណាមួយសមស្រប គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំមកធនាគារជាតិនៃកម្ពុជា និងត្រូវបង់សោហ៊ុយចំនួន ១.០០០.០០០រៀល (មួយលានរៀល)។

ក្នុងករណីប្តូរនាមករណ៍ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណជាថ្មី ដោយភ្ជាប់ជាមួយនូវសំណុំឯកសារ និងបង់សោហ៊ុយពាក់ព័ន្ធចំនួន ១.០០០.០០០រៀល (មួយលានរៀល)។

**ប្រការ ៦.**

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុនដែលទទួលអាជ្ញាបណ្ណត្រូវប្រកបអាជីវកម្មនៅលើទីតាំងដែលបានដាក់ពាក្យស្នើសុំមកធនាគារជាតិនៃកម្ពុជា។

រាល់ការប្តូរទីតាំង គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំមកធនាគារជាតិនៃកម្ពុជា ដោយភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ទីតាំងថ្មីដែលចេញដោយអាជ្ញាធរ និងត្រូវបង់សោហ៊ុយចំនួន ១.០០០.០០០រៀល (មួយលានរៀល)។

**ប្រការ ៧.**

រាល់ការនាំចេញ ឬនាំចូលលោហធាតុមានតម្លៃ និង/ឬ ត្បូងថ្មមានតម្លៃ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវស្នើសុំប្រតិវេទន៍ជាមុនពីធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងអំពីការសម្រេចអនុញ្ញាតផ្តល់ប្រតិវេទន៍ក្នុងរយៈពេល ៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យស្នើសុំ។

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវបង់សោហ៊ុយប្រតិវេទន៍ចំនួន២.០០០.០០០ រៀល (ពីរលានរៀល)។

ពាក្យស្នើសុំប្រតិវេទន៍ត្រូវភ្ជាប់ជាមួយនូវ ៖

ក. ឯកសារដែលបានព្រមព្រៀងគ្នាជាមួយដៃគូក្នុងការនាំចេញ-នាំចូលលោហធាតុឬត្បូងថ្មមានតម្លៃដោយមានបញ្ជាក់ច្បាស់នូវ ប្រភេទទំនិញ តម្លៃក្នុងឯកតា តម្លៃសរុប និងបរិមាណ លក្ខខណ្ឌទូទាត់ លក្ខខណ្ឌប្រគល់ទទួល កាលបរិច្ឆេទប្រគល់ទទួលថ្លៃប្រសិទ្ធភាពទូទាត់

ខ. ឯកសារដែលបញ្ជាក់នូវឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទទំនាក់ទំនង និងអ៊ីម៉ែល របស់ដៃគូនាំចេញ-នាំចូលឱ្យបានច្បាស់លាស់ និងឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទទំនាក់ទំនង និងអ៊ីម៉ែលរបស់អាជ្ញាធរដែលផ្តល់អាជ្ញាបណ្ណដល់ដៃគូនោះ។

ធនាគារជាតិនៃកម្ពុជា នឹងពិនិត្យ សម្រេច អនុញ្ញាតលើពាក្យស្នើសុំនីមួយៗ មិនឱ្យលើសពី ១.០០០ គីឡូក្រាម (មួយពាន់គីឡូក្រាម)។

ប្រតិវេទន៍នាំចេញ ឬនាំចូលនូវលោហធាតុ ឬត្បូងថ្មមានតម្លៃមានសុពលភាព ៣០ថ្ងៃ ចាប់ពីថ្ងៃចុះហត្ថលេខា និងអាចប្រើប្រាស់បាន ២ដង។

**ប្រការ ៨.**

បន្ទាប់ពីបាននាំចេញ ឬនាំចូលលោហធាតុ និង/ឬ ត្បូងថ្មមានតម្លៃរួច គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនត្រូវបញ្ជូនប្រតិវេទន៍ (សន្លឹកពណ៌លឿង) ដែលត្រូវបានមន្ត្រីគយនិងរដ្ឋាករចុះទិដ្ឋាការនៅផ្នែកខាងខ្នង ព្រមទាំងសក្ខីបត្របញ្ជាក់ពីការទូទាត់តាមរយៈធនាគារ មកធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល ១៥ថ្ងៃនៃថ្ងៃធ្វើការដើម្បីជាសេចក្តីរាយការណ៍។

**ប្រការ ៩.**

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលបានទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តតាមគោលការណ៍កំណត់ដូចខាងក្រោមក្នុងការធ្វើអាជីវកម្មរបស់ខ្លួន៖

ក. តាំងឈ្មោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុន នៅលើទីតាំងដែលបានទទួលការអនុញ្ញាត។

ខ. តាំងបង្ហាញជាសាធារណៈនូវអាជ្ញាបណ្ណដែលបានទទួលពីធនាគារជាតិនៃកម្ពុជា។

គ. ប្រកបអាជីវកម្មនៅលើទីតាំងដែលអាជ្ញាធរមានសមត្ថកិច្ចបានអនុញ្ញាត ដូចមានចែងនៅក្នុងឯកសារពាក្យស្នើសុំអាជ្ញាបណ្ណ។

**ប្រការ ១០.**

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលបានទទួលអាជ្ញាបណ្ណត្រូវផ្តល់របាយការណ៍ប្រចាំឆមាសស្តីពីសកម្មភាពនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃរបស់ខ្លួនមកធនាគារជាតិនៃកម្ពុជាឱ្យបានមុនថ្ងៃទី១៥ នៃខែដែលត្រូវរាយការណ៍។

ធនាគារជាតិនៃកម្ពុជានឹងចុះត្រួតពិនិត្យ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលធ្វើអាជីវកម្មនេះតាមការចាំបាច់។

**ប្រការ ១១.**

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលស្ថិតនៅក្រោមប្រកាសនេះ ត្រូវចូលរួមសហការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដើម្បីធានាបាននូវប្រសិទ្ធភាព ក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅក្នុងប្រទេសកម្ពុជា។

**ប្រការ ១២.**

ក្នុងករណីបញ្ឈប់សកម្មភាព គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុន ត្រូវដាក់ពាក្យស្នើសុំបញ្ឈប់អាជីវកម្មរបស់ខ្លួនដោយបញ្ជាក់ពីមូលហេតុ និងភ្ជាប់មកជាមួយនូវអាជ្ញាបណ្ណច្បាប់ដើមមកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេលយ៉ាងតិច ៣០ថ្ងៃមុនបញ្ឈប់អាជីវកម្ម។

**ប្រការ ១៣.**

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុន ដែលមានអាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ ដែលមិនបានផ្ញើរបាយការណ៍តាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា នឹងត្រូវរងការពិន័យដូចមានចែងក្នុងប្រការ ១៤ ខាងក្រោម។

**ប្រការ ១៤.**

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ស្តីពីសកម្មភាពនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃជូនធនាគារជាតិនៃកម្ពុជាលើសពីរយៈពេលកំណត់ដូចមានចែងក្នុងប្រការ ១០ នឹងត្រូវរងការពិន័យជាប្រាក់ចំនួន ១០០.០០០រៀល (មួយរយពាន់រៀល) ក្នុងមួយថ្ងៃរយៈពេល ១៥ថ្ងៃ។

ករណីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនមិនបានផ្ញើរបាយការណ៍ស្តីពីសកម្មភាពនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ និងមិនបង់ប្រាក់ពិន័យខាងលើទាន់ពេលវេលា គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុននោះនឹងត្រូវរងការព្យួរអាជ្ញាបណ្ណមិនឱ្យធ្វើប្រតិបត្តិការរយៈពេល ១ខែ។ នៅក្នុងរយៈពេលព្យួរនេះ ប្រសិនបើមានបំណងធ្វើប្រតិបត្តិការឡើងវិញ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុននោះត្រូវដាក់ពាក្យសុំធ្វើអាជីវកម្មជាថ្មី និងបង់ប្រាក់ពិន័យពាក់ព័ន្ធ។ ប្រសិនបើមិនបានដាក់ពាក្យសុំធ្វើអាជីវកម្មឡើងវិញនៅក្នុងរយៈពេលព្យួរទេ នៅពេលផុតរយៈពេលព្យួរអាជ្ញាបណ្ណ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុននោះនឹងត្រូវរងការដកហូតអាជ្ញាបណ្ណ។

ព័ត៌មានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនស្តីពីការទទួលបានអាជ្ញាបណ្ណ រងការព្យួរអាជ្ញាបណ្ណ ឬដកហូតអាជ្ញាបណ្ណ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ។

**ប្រការ ១៥.**

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុន ដែលបាននាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ ដោយមិនបានសុំប្រតិវេទន៍ពីធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុននោះនឹងត្រូវផ្តន្ទាទោស ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់។

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលផ្តល់ព័ត៌មានខុស ឬបំភាន់នឹងត្រូវពិន័យជាប្រាក់ ១០.០០០.០០០ រៀល (ដប់លានរៀល) និង/ឬ ដកហូតអាជ្ញាបណ្ណ។

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ ឬបទបញ្ជាពាក់ព័ន្ធនឹងសកម្មភាពរបស់ខ្លួន ឬមិនបានធ្វើតាមការដាស់តឿន ឬមិនបានធ្វើតាមអធិបញ្ញាអាជ្ញាធរ អាណាព្យាបាល អាចរងទណ្ឌកម្មខាងវិន័យណាមួយ ដូចខាងក្រោម៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ហាមធ្វើប្រតិបត្តិការក្នុងរយៈពេលណាមួយតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា
- ព្យួរអាជ្ញាបណ្ណក្នុងរយៈពេលណាមួយតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា
- ដកហូតអាជ្ញាបណ្ណជាស្ថាពរ

**ប្រការ ១៦.**

ប្រកាសលេខ ធ៩.០៩.២៦២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូល លោហធាតុនិងត្បូងថ្មមានតម្លៃ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៧.**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គពិនិត្យ អគ្គបេឡា ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១៨.**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣កើត ខែ ពិសាខ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ២០២១

**ទេសាភិបាល**

**ជា ចាន់តូ**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ១៧ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារជាតិនៃកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់អភិបាលរាជធានី-ខេត្ត "ដើម្បីជូនជ្រាប និងសហការអនុវត្ត"
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងពាណិជ្ជកម្ម